# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញាឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ ស្ដីពីគោលការណ៍រួមនៃការបង្កើត និងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ស្ដីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព
- បានឃើញអនុក្រឹត្យលេខ ២០៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧ ស្ដីពីការកែសម្រួលកិរិតប្រាក់ឧបត្ថម្ភសមាជិកកន្សោមអាទិភាព
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេសនៅតាមបណ្តាអង្គភាពសុខាភិបាល នៃក្រសួងសុខាភិបាលក្នុងជំហានដំបូងចំនួន ៣០ ដែលមានដូចខាងក្រោម :

១- មន្ទីរពេទ្យបង្អែកខេត្ត កោះកុង
២- មន្ទីរពេទ្យបង្អែកខេត្ត រតនគីរី
៣- មន្ទីរពេទ្យបង្អែកខេត្ត មណ្ឌលគីរី
៤- មន្ទីរពេទ្យបង្អែកខេត្ត ព្រះវិហារ
៥- មន្ទីរពេទ្យបង្អែកខេត្ត កំពង់ចាម
៦- មន្ទីរពេទ្យបង្អែកខេត្ត ឧត្តរមានជ័យ
៧- មន្ទីរពេទ្យបង្អែកខេត្ត សៀមរាប
៨- មន្ទីរពេទ្យបង្អែកខេត្ត តាកែវ
៩- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិគីរីវង់ ខេត្តតាកែវ
១០- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិអង្គរកា ខេត្តតាកែវ
១១- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រៃកប្បាស ខេត្តតាកែវ
១២- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាទី ខេត្តតាកែវ
១៣- មណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិដូនកែវ ខេត្តតាកែវ
១៤- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិមេមត់ ខេត្តកំពង់ចាម
១៥- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពញាក្រែក ខេត្តកំពង់ចាម
១៦- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិជើងព្រៃ ខេត្តកំពង់ចាម
១៧- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំការលើ ខេត្តកំពង់ចាម
១៨- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រៃឈរ ខេត្តកំពង់ចាម

១៩- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រះស្តេច ខេត្តព្រៃវែង

២០- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង

២១- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្មាច់មានជ័យ ខេត្តកោះកុង

២២- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្រែអំបិល ខេត្តកោះកុង

២៣- មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបានលុង ខេត្តរតនគិរី

២៤- មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសែនមនោរម្យ ខេត្តមណ្ឌលគីរី

២៥- មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិត្បែងមានជ័យ ខេត្តព្រះវិហារ

២៦- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសូទ្រនិគម ខេត្តសៀមរាប

២៧- មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសៀមរាប ខេត្តសៀមរាប

២៨- មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិអង្គរជុំ ខេត្តសៀមរាប

២៩- មន្ទីរពេទ្យបង្អែកស្រុក និងមណ្ឌលសុខភាព ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិក្រឡាញ់ ខេត្តសៀមរាប

៣០- មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសំរោង ខេត្តឧត្តរមានជ័យ ។

**មាត្រា ២.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ គឺជាភ្នាក់ងារមួយរបស់ក្រសួងសុខាភិបាល ដែលមានមុខងារពិសេសក្នុងការផ្តល់សេវាសុខាភិបាលជូនប្រជាពលរដ្ឋ ហើយស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងសុខាភិបាល និងមានភារកិច្ចចម្បងៗ ដូចខាងក្រោម :

- ផ្តល់សេវាសុខភាពសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា

- លើកកំពស់ការគ្រប់គ្រងផ្អែកលើលទ្ធផលការងារ ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព សំដៅកែប្រែផ្នត់គំនិត និងអាកប្បកិរិយាមន្ត្រីរាជការ ស្របតាមលក្ខណសម្បត្តិរបស់រដ្ឋបាលសាធារណៈ
- អភិវឌ្ឍសមត្ថភាពក្នុងការផ្តល់សេវាសុខាភិបាលសាធារណៈ ។

ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនីមួយៗមានតួនាទីសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងការងារគ្រប់គ្រងដល់អង្គភាពសុខាភិបាលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

**មាត្រា ៣.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេសដែលជាមន្ទីរពេទ្យបង្អែកខេត្ត ដូចមានចែងក្នុងមាត្រា ១ ត្រូវដឹកនាំ និងគ្រប់គ្រង ដោយប្រធានមន្ទីរពេទ្យបង្អែកខេត្តនីមួយៗ ។

ទីភ្នាក់ងារប្រតិបត្តិការពិសេសដែលស្ថិតនៅតាមបណ្តាការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដូចមានចែងក្នុងមាត្រា ១ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិនីមួយៗ ។

**មាត្រា ៤.-**

សិទ្ធិ និងការទទួលខុសត្រូវរបស់ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងល័ក្ខខ័ណ្ឌបេសកកម្ម និងក្នុងកិច្ចសន្យាគ្រប់គ្រង ។

ល័ក្ខខ័ណ្ឌបេសកកម្ម និងកិច្ចសន្យាគ្រប់គ្រងគំរូ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនៃបណ្តាអង្គភាពសុខាភិបាលនីមួយៗ ត្រូវទទួលខុសត្រូវក្នុងដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះប្រធានមន្ទីរសុខាភិបាលខេត្ត ដែលទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ ។

**មាត្រា ៦.-**

មន្ត្រីដែលបម្រើការងារក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៅតាមបណ្តាអង្គភាព នៃក្រសួងសុខាភិបាលដូចបានកំណត់ក្នុងមាត្រា ១ ជាមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ឬ បុគ្គលិកជាប់កិច្ចសន្យាដែលកំពុងបម្រើការងារក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់ក្រសួងសុខាភិបាល ។

មន្ត្រីរាជការ និងបុគ្គលិកទាំងនេះ ត្រូវចុះកិច្ចសន្យាការងារជាមួយប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ តាមរយៈអ្នកគ្រប់គ្រងមន្ត្រីផ្ទាល់ ។

**មាត្រា ៧.-**

មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ដែលបម្រើការងារនៅក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ដែលបានមកពីការបែងចែកប្រាក់សេវាហិរញ្ញប្បទាន ប្រាក់ធានារ៉ាប់រងសង្គម ប្រាក់មូលនិធិសមធម៌ និងប្រាក់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ បន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ។

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តខាងលើនេះ ត្រូវអនុវត្តតាមកំរិតប្រាក់ឧបត្ថម្ភនៃកម្មវិធីកន្សោមអាទិភាព ។ បន្ថែមលើនេះ ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗអាចផ្តល់ជូនប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់មន្ត្រី និងបុគ្គលិកទៅតាមលទ្ធផលការងារ និងស្ថានភាពជាក់ស្តែងនៃទីកន្លែង ដែលទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ ។

**មាត្រា ៨.-**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវធ្វើឡើងនៅតាមអង្គភាព ដែលទីភ្នាក់ងារប្រតិបត្តិការពិសេសគ្រប់ដណ្តប់ ។

**មាត្រា ៩.-**

ប្រភពធនធាន និងចំណូលថវិការបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសនៃក្រសួងសុខាភិបាលបានមកពី :

- ថវិកាជាតិ
- ប្រាក់សេវាហិរញ្ញប្បទាន
- ប្រាក់ធានារ៉ាប់រងសង្គម
- ប្រាក់មូលនិធិសមធម៌ និង
- ប្រាក់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ។

**មាត្រា ១០.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍វិស័យសុខាភិបាលត្រូវធានាថវិកាដែលត្រូវផ្តល់ឱ្យទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗបានទាន់ពេលវេលា ។

ទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលជាសេនាធិការមានតួនាទីសម្របសម្រួល ជំរុញ និងតាមដានការអនុវត្តន៍របស់ទីភ្នាក់ងារប្រតិបត្តិការពិសេសទាំងនេះ។

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច ✓
- ឯកសារ -កាលប្បវត្តិ